## សំរេច

**មាត្រា ១ :** អនុញ្ញាតអោយផ្ទេរឥណទាន ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ( ឥណទានសំរាប់សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម ) ជូនទៅក្រសួង អប់រំ យុវជន និង កីឡានូវបរិមាណដូចខាងក្រោម :

- ជំពូក ១០ : ២៣.០៤៨.៦៨៣ " បៀវត្ស និង ប្រាក់បំណាច់ "
- ជំពូក ១១ : ២៣.៥៩១.០០០ " ចំណាយដំណើរការរដ្ឋបាលសំភារៈជួសជុលតូច "
- ជំពូក ៣១ : ៣.០៨០.០០០ " អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ "
- ជំពូក ៥១ : ២.០០០.០០០ " ឥណទានទិញសំភារៈ "

សរុប : ៥១.៧១៩.៦៨៣ ( ហាសិបមួយលានប្រាំពីររយដប់ប្រាំបួនពាន់ប្រាំមួយរយកៅសិបបីរៀល )

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៥០ អនក្រ
## ស្តីពីការលុបចោលលិខិតបជ្ជានចំនួនបី ដែលមិនសមស្របរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

## សំរេច

**មាត្រា ១ :** លុបចោលសេចក្តីប្រកាសលេខ ០៦៤ ប្រ.កសហវ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតកំរៃទទួលខុសត្រូវដល់គណនេយ្យសាធារណៈនិងមន្ត្រីរាជការរតនាគារ ។

**មាត្រា ២ :** លុបចោលចំណុចទី ៥ នៃសេចក្តីសំរេចរបស់អង្គប្រជុំប្រចាំសប្តាហ៍ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុស្តីពីប្រាក់ឧបត្ថម្ភ បេសកកម្ម ដោយឡែករបស់មន្ត្រីរាជការក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ៣ :** លុបចោលសេចក្តីប្រកាសលេខ ០៩៧ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការអនុវត្តនីតិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិង Inchscape Tesfing services International Limited លើអធិការកិច្ចទំនិញនាំចូល មុនពេលផ្ទុកលើមធ្យោបាយដឹកជញ្ជូន ។

**មាត្រា ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៥ អនក្រ
## ស្តីពីការជួនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា